ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣*៤

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ.០០៦........សរណន.សអយ

# សារាចរណែនាំ
# ស្តីពី
# ការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

ដើម្បីអនុវត្តអោយមានប្រសិទ្ធភាពតាមមាត្រា ៣ នៃអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំអនុវត្តដូចតទៅ :

## I- របៀបគណនាប្រាក់សោធនថ្មីរបស់និវត្តជន និងជនពិការបាត់បង់សម្បទាវិជ្ជាជីវៈ

និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធនកន្លងមក ត្រូវបានកែសំរួលប្រាក់សោធនតាមការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដោយគណនាតាមរូបមន្តដូចខាងក្រោម :

| |
|---|
| **ប្រាក់សោធនសរុបប្រចាំខែថ្មី-ប្រាក់សោធនសុទ្ធសាធប្រចាំខែចាស់+ ១៥%នៃប្រាក់សោធនសុទ្ធសាធប្រចាំខែចាស់ + ប្រាក់ឧបត្ថម្ភផ្សេងៗ** |

- ចំពោះនិវត្តជនដែលមានប្រាក់សោធនសុទ្ធសាធប្រចាំខែទាបជាងប្រាក់បៀវត្សមូលដ្ឋានអប្បបរមានៃតារាងកាំ-ប្រាក់របស់សាមីខ្លួន ការគណនាប្រាក់ដំឡើង ១៥ % នៃប្រាក់សោធនសុទ្ធសាធគឺត្រូវយកប្រាក់បៀវត្សមូលដ្ឋានអប្បបរមានោះគុណនឹង១៥ % ។

- ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានប្រាក់សោធនសុទ្ធសាធប្រចាំខែទាបជាង ៥០%នៃប្រាក់បៀវត្សមូលដ្ឋានអប្បបរមានៃតារាងកាំប្រាក់របស់សាមីខ្លួន ការគណនាប្រាក់ដំឡើង ១៥% នៃប្រាក់សោធនសុទ្ធសាធគឺត្រូវយក ៥០% នៃប្រាក់បៀវត្សមូលដ្ឋានអប្បបរមានោះគុណនឹង ១៥% ។

**ឧទាហរណ៍ទី ១ :**

និវត្តជនម្នាក់មានតារាងកាំប្រាក់ ឃ១.១= ៥២ ៥០០៖០០ ។ ពេលចូលនិវត្តន៍គាត់មានភាគរយប្រាក់សោធននិវត្តន៍ស្មើនឹង ៨០%នៃបៀវត្សមូលដ្ឋានរបស់គាត់ ។មុនពេលធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល គាត់មានប្រាក់សោធន



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ,ទូរស័ព្ទ /ទូរសារៈ (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726086

និវត្តន៍សុទ្ធសាធប្រចាំខែចំនួន ៥៧ ៧៥០៛០០ ។ ដូច្នេះការគណនាប្រាក់សោធននិវត្តន៍របស់គាត់គឺ:

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៥២ ៥០០៛០០ x ៨០% = ៤២ ០០០៛០០
- ប្រាក់បៀវត្សមូលដ្ឋានអប្បបរមានៃតារាងកាំប្រាក់ ឃ១.៦ = ៤២ ៣០០៛០០
- ប្រាក់បន្ថែមអោយស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៣០០៛០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៤២ ៣០០៛០០
- ប្រាក់មង្គ្រប់ = ១៥ ០០០៛០០
- ប្រាក់បន្ថែមអោយស្មើប្រាក់សោធននិវត្តន៍ចាស់ = ៤៥០៛០០
- ប្រាក់ដំឡើង ១៥%នៃប្រាក់សោធននិវត្តន៍សុទ្ធសាធ ៤២ ៣០០៛០០ x ១៥% = ៦ ៣៤៥៛០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធថ្មី ៤២ ៣០០៛០០ + ៦ ៣៤៥៛០០ = ៤៨ ៦៤៥៛០០

ដូច្នេះប្រាក់សោធននិវត្តន៍ប្រចាំខែដែលត្រូវទទួល=៤៨ ៦៤៥៛+១៥ ០០០៛+៤៥០៛ = ៦៤ ០៩៥៛០០

**ឧទាហរណ៍ទី ២:**

ជនបាត់បង់សម្បទាវិជ្ជាជីវៈម្នាក់មានតារាងកាំប្រាក់ គ៣-១៤ = ៤៥ ០០០៛០០ ។ ពេលចូលបាត់បង់សម្បទាវិជ្ជាជីវៈ គាត់មានភាគរយប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ស្មើនឹង ៦៥% នៃបៀវត្សមូលដ្ឋានរបស់គាត់ ។ ដូច្នេះការគណនាប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈរបស់គាត់គឺ:

- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធប្រចាំខែ ៤៥ ០០០៛០០ x ៦៥% = ២៩ ២៥០៛០០
- ៩០%នៃប្រាក់បៀវត្សមូលដ្ឋានអប្បបរមា គ៣.១៤ =៤៥ ០០០៛០០ x ៩០% = ៤០ ៥០០៛០០
- ប្រាក់បន្ថែមអោយស្មើនឹង ៩០%នៃបៀវត្សមូលដ្ឋានអប្បបរមា = ១១ ២៥០៛០០
- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធប្រចាំខែស្មើនឹង ៩០%នៃបៀវត្សមូលដ្ឋានអប្បបរមា
= ៤០ ៥០០៛០០
- ប្រាក់ដំឡើង ១៥%នៃប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធ
៤០ ៥០០៛០០ x ១៥% = ៦ ០៧៥៛០០

ដូច្នេះប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែដែលត្រូវទទួល
៤០ ៥០០៛០០ + ៦ ០៧៥៛០០ = ៤៦ ៥៧៥៛០០

ការបូកបន្ថែម ១៥ % នៃប្រាក់សោធនសុទ្ធសាធរបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តចាប់ពីខែ មករា ឆ្នាំ ២០០៥ នេះតទៅ ។

## II-របៀបគណនាប្រាក់សោធនរបស់មន្ត្រីរាជការចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ,ទូរស័ព្ទ /ទូរសារ: (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726086

ក- ប្រាក់សោធនរបស់មន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ត្រូវបានបូកបន្ថែម១៥%នៃប្រាក់សោធនសុទ្ធសាធប្រចាំខែរបស់សាមីជន ដោយគណនាតាមរូបមន្តដូចខាងក្រោម :

| |
|---|
| **ប្រាក់សោធនសរុបប្រចាំខែ = ប្រាក់សោធនសុទ្ធសាធប្រចាំខែ + ១៥% នៃប្រាក់សោធនសុទ្ធសាធប្រចាំខែ + ប្រាក់ឧបត្ថម្ភផ្សេងៗ** |

ប្រាក់សោធនសុទ្ធសាធប្រចាំខែត្រូវគណនាលើប្រាក់បៀវត្សមូលដ្ឋានចាស់ ។

ខ-ប្រាក់សោធនរបស់មន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៥ តទៅ ត្រូវគណនាតាមរូបមន្តដូចខាងក្រោម :

| |
|---|
| **ប្រាក់សោធនសរុបប្រចាំខែ = ប្រាក់សោធនសុទ្ធសាធប្រចាំខែ + ប្រាក់ឧបត្ថម្ភផ្សេងៗ** |

ប្រាក់សោធនសុទ្ធសាធប្រចាំខែត្រូវគណនាលើប្រាក់បៀវត្សមូលដ្ឋានថ្មី ។

**ឧទាហរណ៍ ទី ៣**

មន្ត្រីម្នាក់មានតារាងកាំប្រាក់ ឃ១-១= ៦០ ៣៧៥៛០០ ត្រូវចូលនិវត្តន៍នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៥ ។ពេលចូលនិវត្តន៍គាត់មានភាគរយសោធននិវត្តន៍ស្មើនឹង ៨០% ។ មុនពេលធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល បើគណនាប្រាក់សោធននិវត្តន៍សុទ្ធសាធរបស់គាត់គឺមានចំនួន ៦៤ ០៩៥៛០០ ។ ដូច្នេះការគណនាប្រាក់សោធននិវត្តន៍សុទ្ធសាធរបស់គាត់គឺ:

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៦០ ៣៧៥៛០០ x ៨០% = ៤៨ ៣០០៛០០
- ប្រាក់បៀវត្សមូលដ្ឋានអប្បបរមា ឃ១-៦ = ៤៨ ៦៤៥៛០០
- ប្រាក់បន្ថែមអោយស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៣៤៥៛០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៤៨ ៦៤៥៛០០
- ប្រាក់បង្គ្រប់ = ១៥ ០០០៛០០
- ប្រាក់បន្ថែមអោយស្មើប្រាក់សោធននិវត្តន៍ចាស់ = ៤៥០៛០០

ដូច្នេះប្រាក់សោធននិវត្តន៍ប្រចាំខែដែលត្រូវទទួល=៤៨ ៦៤៥៛ + ១៥ ០០០៛ + ៤៥០៛ = ៦៤ ០៩៥៛០០

គ-ទម្រង់បែបបទស្នើសុំ ប្រាក់សោធនថ្មី

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង ត្រូវធ្វើលិខិតស្នើសុំកែប្រែប្រាក់សោធនប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយភ្ជាប់មកជាមួយនូវៈ

- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ប្រចាំខែចុងក្រោយ ចំនួន ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈថ្មី ចំនួន ០១ ច្បាប់

បន្ទាប់ពីបានទទួលការយល់ព្រមជាគោលការណ៍ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា លើតារាង



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ,ទូរស័ព្ទ /ទូរសារ: (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726086

ប្រាក់សោធនថ្មីមក ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង មានសិទ្ធិចុះហត្ថលេខានៅលើទំព័រ "ប្តូរប្រាក់បៀវត្សគិតពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥" របស់សៀវភៅនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ។

សារាចរណែនាំលេខ ០០៣ សរណន.សអយ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៥ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការកែប្រែឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ត្រូវចាត់ទុកជានិរាករណ៍ ។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០០៥

**ឧ.ន.ម**

**អ៊ិត សំហេង**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- គ្រប់សាលា ខេត្ត - ក្រុង

  " ដើម្បីជូនជ្រាបជាពត៌មាន "
- គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
- គ្រប់មន្ទីរ ស អ យ ខេត្ត - ក្រុង

  " ដើម្បីសហការអនុវត្ត "
- ឯកសារ - កាលប្បវត្តិ